អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អ.វ.ត.ក នឹងចែកសៀវភៅសាលដីកាក្នុងសំណុំរឿង ០០១ ជូនដល់អ្នករស់រានមានជីវិតពីមន្ទីរ ស-២១ និងដើមបណ្តឹងរដ្ឋប្បវេណី

ផ្នែកកិច្ចការសាធារណៈនិងអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងចែកសៀវភៅសាលដីកាក្នុងសំណុំរឿង ០០១ ជូនដល់អ្នករស់រានមានជីវិតពីមន្ទីរ ស-២១ និងដើមបណ្តឹងរដ្ឋប្បវេណី ***នៅថ្ងៃសុក្រ ទី១៨ ខែឧសភា ឆ្នាំ២០១២ វេលាម៉ោង ១:៣០ នាទីរសៀល*** នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ ផ្នែកកិច្ចការសាធារណៈសូមអញ្ជើញតំណាងសារព័ត៌មានជាតិនិងអន្តរជាតិចូលរួមក្នុងកម្មវិធីនេះ។ ***អ្នកសារព័ត៌មានដែលមកចូលរួម សូមពាក់ប័ណ្ណសារព័ត៌មានដែលផ្តល់ជូនដោយ អ.វ.ត.ក ឬដោយស្ថាប័នសារព័ត៌មាន។***

សំណុំរឿង ០០១ គឺជាសំណុំរឿងទីមួយដែលត្រូវបានជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក។ សំណុំរឿងនេះបានបិទបញ្ចប់នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលពេលនោះ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីកាផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ដើម្បីឲ្យសាធារណជនកម្ពុជាបានទទួលព័ត៌មានលម្អិតអំពីសាលដីកានេះ អ.វ.ត.ក បានបោះពុម្ពសាលដីកាទាំងស្រុងជាភាសាខ្មែរចំនួន ៥ ០០០ ច្បាប់ និងសាលដីកាសង្ខេបជាភាសាខ្មែរចំនួន ១៥ ០០០ ច្បាប់ ដើម្បីចែកជូនដើមបណ្តឹងរដ្ឋប្បវេណី ស្ថាប័នតុលាការក្នុងស្រុក សាកលវិទ្យាល័យ បណ្ណាល័យ និងមន្ទីរក្រសួងនៅក្នុងរដ្ឋាភិបាល។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឌឹម សុវណ្ណារ៉ុម**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៨៦១ ៥២៩
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ០៩៤
សារអេឡិចត្រូនិក៖ dim.sovannarom@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៨៦១ ៦៦៩
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិចត្រូនិក៖ olsenl@un.org

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh